ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ : ៣៧៦១ មស.សសវ

# សេចក្ដីសម្រេច
# ស្ដីពី
# ការបង្កើតគណៈកម្មការជ្រើសរើសមន្ត្រីដឹកនាំគ្រប់គ្រង នៃក្រសួងមុខងារសាធារណៈ

## រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃទីស្ដីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២១ ស្ដីពីការកែសម្រួលរចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់អង្គភាពចំណុះក្រសួងមុខងារសាធារណៈ
- សេចក្ដីជូនដំណឹងលេខ ៣១៣៤ មស.សជណ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១ របស់ក្រសួងមុខងារសាធារណៈ
- យោងតាមសំណូមពរចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើត **គណៈកម្មការជ្រើសរើសមន្ត្រីដឹកនាំគ្រប់គ្រង នៃក្រសួងមុខងារសាធារណៈ** ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១. ឯកឧត្តម | **ហ៊ុំ សុខា** | រដ្ឋមន្ត្រី | ប្រធាន |
| ២. ឯកឧត្តម | **អែម ម៉ុនធុល** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៣. ឯកឧត្តម | **ហាន្ស ឆាំឆាន** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៤. ឯកឧត្តម | **ហួត ស៊ីនាដ** | អនុរដ្ឋលេខាធិការ | សមាជិក |
| ៥. ឯកឧត្តម | **ហេង ពិសាល** | ទីប្រឹក្សា | សមាជិក |

| | | | |
|---|---|---|---|
| ៦. ឯកឧត្តម | **កោង ឈាង** | ទីប្រឹក្សា | សមាជិក |
| ៧. ឯកឧត្តម | **ឌុច ដារិន្ទ** | ទីប្រឹក្សា | សមាជិក |
| ៨. ឯកឧត្តម | **យឿន សម្បត្តិ** | អគ្គនាយក | សមាជិក |
| ៩. ឯកឧត្តម | **ហាស់ ម៉ិនថុន** | អគ្គនាយក | សមាជិក |
| ១០. លោក | **សយ រតនៈ** | ប្រធាននាយកដ្ឋាន | សមាជិក |
| ១១. លោក | **សួន រស្មី** | ប្រធាននាយកដ្ឋាន | សមាជិក |
| ១២. លោក | **សូលី វណ្ណាម៉ុក** | ប្រធាននាយកដ្ឋាន | សមាជិកអចិន្ត្រៃយ៍ |

**ប្រការ២.** -

គណៈកម្មការនេះមានភារកិច្ច ដូចតទៅ៖

- ធ្វើការផ្សព្វផ្សាយទូលំទូលាយដល់មន្ត្រីរាជការទាំងអស់នៃក្រសួងមុខងារសាធារណៈ ពីការជ្រើសរើសមន្ត្រីដឹកនាំគ្រប់គ្រង ដើម្បីទទួលមុខតំណែងដែលនៅទំនេរជាអនុប្រធាននាយកដ្ឋាន និងប្រធានការិយាល័យក្នុងរចនាសម្ព័ន្ធដែលបានកែសម្រួល
- រៀបចំយន្តការ និងនីតិវិធី ដើម្បីចាត់ចែងដំណើរការនៃការជ្រើសរើស
- កំណត់វិធីសាស្ត្រនៃការពិនិត្យ វិនិច្ឆ័យ លក្ខណៈសម្បត្តិសមស្របសម្រាប់បេក្ខជនដែលត្រូវបានចម្រាញ់ជ្រើសរើស ដោយផ្អែកលើកម្រិតយល់ដឹង និងពិសោធន៍ការងារតាមរយៈសំណេរល្បងសមត្ថភាព និងសម្ភាសន៍ផ្ទាល់មាត់ ព្រមទាំងលក្ខណៈវិនិច្ឆ័យចាំបាច់ផ្សេងទៀត
- បំពេញកិច្ចការផ្សេងទៀតតាមការចាំបាច់ ។

**ប្រការ៣.**-

ប្រធានអង្គភាពចំណុះក្រសួងរួមមាន ខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានគ្រប់គ្រងមុខងារសាធារណៈ អគ្គនាយកដ្ឋានគោលនយោបាយមុខងារសាធារណៈ អគ្គាធិការដ្ឋាន សាលាភូមិន្ទរដ្ឋបាល គ្រប់អង្គភាពពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១២កើត ខែ ស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

**ព្រុំ សុខា**

**កន្លែងទទួល៖**

- ដូចប្រការ ៣
  " ដើម្បីអនុវត្ត "
- ឯកសារ កាលប្បវត្តិ